PCAsia
PARLIAMENTARY CENTRE OF ASIA
Strengthening Parliamentary Capacity

# ឯកសារជំនួយស្មារតីស្តីពី "ទិដ្ឋភាពខ្លះៗនៃយេនឌ័រទាក់ទង នឹងការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច នៅព្រះរាជាណាចក្រកម្ពុជា"

(លោក ញៀប សិលា និង លោកស្រី រស់ បណ្ណែត)

**ខែតុលា ឆ្នាំ២០២៤**

- មាត្រា២៣នៃច្បាប់ភូមិបាលឆ្នាំ២០០១ កំណត់ច្បាស់ថា ជនជាតិដើមភាគតិច ជាក្រុមមនុស្សដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច និងជាអ្នកប្រកបរបរចិញ្ចឹមជីវិតតាមប្រពៃណី និងដាំដុះលើដីធ្លីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។ ច្បាប់ភូមិបាលមានបទបញ្ញត្តិសំខាន់ៗ ស្តីពី ការការពារដីធ្លីជនជាតិដើមភាគតិច ដែលអនុញ្ញាតឱ្យសហគមន៍ទទួលបានបណ្ណកម្មសិទ្ធិដីធ្លី តាមបែបសហគមន៍ ជាជាងកម្មសិទ្ធិដោយរូបវន្តបុគ្គល។ ការណ៍នេះ នឹងជួយដល់សហគមន៍ជនជាតិដើមភាគតិច ទប់ស្កាត់ការលក់ដូរ និងផ្ទេរកម្មសិទ្ធិដីធ្លីរបស់ពួកគេទៅឱ្យអ្នករស់នៅខាងក្រៅសហគមន៍។
- នៅក្នុងឆ្នាំ២០០៧ រាជរដ្ឋាភិបាលកម្ពុជាបានគាំទ្រនូវសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពី សិទ្ធិជនជាតិដើមភាគតិច ដោយទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចរួមបញ្ចូលទាំងសិទ្ធិលើការកាន់កាប់ ការប្រើប្រាស់ ការអភិវឌ្ឍ និងការគ្រប់គ្រងដីធ្លីផងដែរ។
- នៅក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិច ដោយទទួលស្គាល់ពីទំនាក់ទំនង ដែលមិនអាចកាត់ផ្តាច់ចេញពីគ្នាបាន រវាងជនជាតិដើមភាគតិចទៅនឹងដីធ្លី និងធនធានធម្មជាតិនៅក្នុងសហគមន៍របស់ពួកគេ ហើយរាជរដ្ឋាភិបាលក៏បានចេញនូវអនុក្រឹត្យលេខ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចផងដែរ។
- ដំណើរការក្នុងការទទួលបានបណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា មានភាពស្មុគ្រស្មាញ ដោយមានពាក់ព័ន្ធទៅនឹងក្រសួងចំនួនបី។ ដំណើរការនេះ នៅតែប្រឈមទៅនឹងការពន្យារពេល និងភាពយឺតយ៉ាវ ដែលបណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិជនជាតិដើមភាគតិច ជាពិសេសស្ត្រី ចំពោះការការពារដីសហគមន៍ និងធនធានធម្មជាតិរបស់ខ្លួន ដែលមានសារៈសំខាន់សម្រាប់ការចិញ្ចឹមជីវិត និងការអភិរក្សទំនៀមទម្លាប់ ប្រពៃណី និងវប្បធម៌របស់ពួកគេ។
- ឯកសារជំនួយស្មារតីនេះ ព្យាយាមគូរបង្ហាញនូវផែនទីភូមិសាស្ត្រនៃសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា ដែលបាន ឬ ពុំទាន់បានចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ ដោយផ្អែកតាមអត្រានៃភាពក្រីក្រ និងទិដ្ឋភាពយេនឌ័រ។ **គោលបំណងនៃ**ឯកសារជំនួយស្មារតី**នេះគឺ ដើម្បីផ្តល់ព័ត៌មានដល់សមាជិកសភាកម្ពុជា អំពីវឌ្ឍនភាពនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា និងដើម្បីផ្តល់ព័ត៌មានស្តីពី ទីកន្លែងដែលសភាកម្ពុជាអាចនឹងពិចារណាចុះទៅបំពេញបេសកកម្ម។**

## សារគន្លឹះ

- សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ភាគច្រើនស្ថិតនៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង។ មានតែសហគមន៍ជនជាតិដើមភាគតិចខ្លះ នៅក្នុងខេត្តទាំងបួននេះទេ ដែលទទួលបានបណ្ណកម្មសិទ្ធិដីធ្លី។ ដូច្នេះដំណើរការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា នៅមានភាពយឺតយ៉ាវ។ ដើម្បីបញ្ចប់ដោយជោគជ័យនូវការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាក្នុងរយៈពេលដប់ឆ្នាំខាងមុខ រាជរដ្ឋាភិបាលគួរពិចារណាពន្លឿនដំណើរការចុះបញ្ជីរបស់ខ្លួនឱ្យបានបីដង។
- សភាកម្ពុជា អាចពិចារណាចុះទៅបំពេញបេសកកម្មទៅកាន់បណ្តាខេត្តភាគឦសាននៃប្រទេសកម្ពុជា ជាពិសេសខេត្តរតនគិរី ពីព្រោះបណ្តាខេត្តទាំងនេះមានអត្រានៃភាពក្រីក្រ គ្រួសារដែលស្ត្រីជាមេគ្រួសារ និងអំពើហិង្សាក្នុងគ្រួសារនៅថ្នាក់ស្រុក ក្នុងកម្រិតពីខ្ពស់ទៅមធ្យម (រូបភាពទី១)។ ដូចដែល មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបង្ហាញ អត្រាប្រេវ៉ាឡង់ខ្ពស់នៃអំពើហិង្សាក្នុងគ្រួសារ អាចជាសូចនាករបង្ហាញថា ជម្លោះដីធ្លីអាចកើនឡើងខ្ពស់នៅក្នុងតំបន់ទាំងនោះ[១]។
- តាមរយៈការចុះបេសកកម្មនៅតាមបណ្តាខេត្តទាំងនេះ សមាជិកសភាកម្ពុជា អាចទទួលបានព័ត៌មានជាក់ស្តែងពីបញ្ហាប្រឈម ដែលនាំឱ្យមានការពន្យារពេលក្នុងការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍និងអាចឈ្វេងយល់ពីផលប៉ះពាល់ទៅលើជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច ជាពិសេសទៅលើស្ត្រី ដើម្បីសិក្សា និងលើកជាអនុសាសន៍ ដែលអាចជួយពន្លឿនដំណើរការចុះបញ្ជី ក៏ដូចជាដើម្បីជួយដោះស្រាយផលប៉ះពាល់នានាផងដែរ។

*រូបភាពទី១៖ សេចក្តីសង្ខេបនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិចតាមបណ្តាខេត្ត បែងចែកតាមអត្រានៃភាពក្រីក្រ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងអំពើហិង្សាក្នុងគ្រួសារ*

| ល.រ | ខេត្ត | ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលកំណត់ដោយក្រសួងអភិវឌ្ឍន៍ជនបទ | ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី | អត្រានៃភាពក្រីក្រនៅតាមបណ្តាខេត្ត | គ្រួសារដែលស្ត្រីជាមេគ្រួសារនៅតាមបណ្តាស្រុក | គ្រួសារដែលរងអំពើហិង្សាក្នុងគ្រួសារនៅតាមបណ្តាស្រុក |
|---|---|---|---|---|---|---|
| ១ | រតនគិរី | ៧៥ | ២៧ | ខ្ពស់ | មធ្យម/ទាប | ខ្ពស់/មធ្យម |
| ២ | មណ្ឌលគិរី | ២៨ | ៧ | ខ្ពស់ | មធ្យម/ទាប | ខ្ពស់/មធ្យម/ទាប |
| ៣ | ស្ទឹងត្រែង | ១៤ | ២ | មធ្យម | មធ្យម/ទាប | ខ្ពស់/ទាប |
| ៤ | ក្រចេះ | ១៣ | ៤ | ខ្ពស់ | ទាប | ខ្ពស់/មធ្យម |
| ៥ | ព្រះវិហារ | ៩ | 0 | មធ្យម | មធ្យម/ទាប | ខ្ពស់/មធ្យម |
| ៦ | កំពង់ធំ | ៥ | 0 | ខ្ពស់ | មធ្យម | ខ្ពស់ |
| ៧ | កំពង់ស្ពឺ | ៥ | 0 | មធ្យម | មធ្យម | ខ្ពស់ |
| ៨ | កោះកុង | ៣ | 0 | ខ្ពស់ | ខ្ពស់ | មធ្យម |
| ៩ | ពោធិសាត់ | ២ | 0 | មធ្យម | មធ្យម | ខ្ពស់ |
| ១០ | បាត់ដំបង | ១ | 0 | ខ្ពស់ | ខ្ពស់ | ខ្ពស់ |

ខ្ពស់ មធ្យម ទាប

## ស្ថានភាពសហគមន៍ជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា

*ផែនទី ទី១៖ សហគមន៍ជនជាតិដើមភាគតិច ដែលកំណត់ដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងឆ្នាំ២០២០*




- រតនគិរី (៧៥)
- មណ្ឌលគិរី (២៨)
- ស្ទឹងត្រែង (១៤)
- ក្រចេះ (១៣)
- ព្រះវិហារ (៩)
- កំពង់ធំ (៥)
- កំពង់ស្ពឺ (៥)
- កោះកុង (៣)
- ពោធិសាត់ (២)
- បាត់ដំបង (១)

**ប្រភពទិន្នន័យ៖** របាយការណ៍ស្តីពី ស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច របស់ជនជាតិដើមភាគតិចនៅកម្ពុជា, ក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ, រាជធានីភ្នំពេញ, ឆ្នាំ២០២១

**ផែនទី ទី១ បង្ហាញថា៖**

- គិតត្រឹមខែមិថុនា ឆ្នាំ២០២១ ក្រសួងអភិវឌ្ឍន៍ជនបទ បានកំណត់នូវអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចចំនួន១៥៥ នៅក្នុងខេត្តចំនួន១០ ក្នុងប្រទេសកម្ពុជា [២] ។
- សហគមន៍ជនជាតិដើមភាគតិច ភាគច្រើនស្ថិតនៅតាមបណ្តាខេត្តភាគឦសានចំនួនបួន រួមមាន ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង [២] ។

*រូបភាពទី២៖ ប្រភេទនៃជនជាតិដើមភាគតិច*




**ប្រភពទិន្នន័យ៖** របាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច របស់ជនជាតិដើមភាគតិចនៅកម្ពុជា, ក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ, រាជធានីភ្នំពេញ, ឆ្នាំ២០២១

- **រូបភាពទី២ បង្ហាញថា៖**
  - ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចនៅកម្ពុជាប្រមាណ ១៦ ៧២៥ គ្រួសារ នៅក្នុង១៥៥សហគមន៍ ដែលក្នុងនោះស្ត្រីមានចំនួន ២៨ ៥១២នាក់ និងបុរសមានចំនួន ៤៥ ០៧៩នាក់ [២]។
  - ជនជាតិដើមភាគតិចនៅកម្ពុជា ត្រូវបានបែងចែកជា៦អំបូរ។ អំបូរទាំងនោះ រួមមាន ព្នង កួយ គ្រឹង ចារាយ ព្រៅ ទំពួន។ ជនជាតិដើមភាគតិចផ្សេងទៀតរួមមាន ការ៉ែត ស្ទួយ ក្រោល កាចក់ ជាដើម[២]។

## ដំណើរការនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច

- អនុក្រឹត្យលេខ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ បានបង្ហាញពីជំហានចំនួនបី សម្រាប់ដំណើរការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច ដោយរួមបញ្ចូលក្រសួងចំនួនបី រួមមាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់[១]។
- យោងតាមគោលការណ៍ណែនាំក្នុងការកំណត់តំបន់សម្រាប់តំបន់ការពារនៅកម្ពុជា និងច្បាប់ស្តីពី ព្រៃឈើឆ្នាំ២០០២ សម្រាប់ដីសហគមន៍ជនជាតិដើមភាគតិច ដែលស្ថិតនៅក្នុងតំបន់សហគមន៍នៃតំបន់ការពារ ឬនៅក្នុងតំបន់ព្រៃអចិន្ត្រៃយ៍ ការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច ត្រូវមានកិច្ចព្រមព្រៀងជាមុន ពីក្រសួងពាក់ព័ន្ធផ្សេងទៀត ដូចជាក្រសួងបរិស្ថាន និង/ឬក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ [៣, ៤]។

*រូបភាពទី៣៖ នីតិវិធីនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច*

**ជំហានទី១)** ក្រសួងអភិវឌ្ឍន៍ជនបទ បានកំណត់អត្តសញ្ញាណសហគមន៍ ជនជាតិដើមភាគតិចចំនួន១៥៥ ត្រឹមឆ្នាំ២០២០

**ជំហានទី២)** ក្រសួងមហាផ្ទៃ បានទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចចំនួន១៥២ ត្រឹមឆ្នាំ២០២០

**ជំហានទី៣)** ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិចចំនួន៤០ ត្រឹមឆ្នាំ២០២៣




**ប្រភពទិន្នន័យ៖** របាយការណ៍ស្តីពីស្ថា នភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច របស់ជនជាតិដើមភាគតិចនៅកម្ពុជា, ក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ, រាជធានីភ្នំពេញ, ឆ្នាំ២០២១ និងប្រព័ន្ធទិន្នន័យនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច , LANDESA, រាជធានីភ្នំពេញ, ឆ្នាំ២០២៤

- **រូបភាពទី៣ បង្ហាញថា៖**
  - ក្រសួងអភិវឌ្ឍន៍ជនបទ បានកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចចំនួន១៥៥ ប៉ុន្តែមានតែ១៥២សហគមន៍ប៉ុណ្ណោះ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ [២] ។
  - ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច១៥៥ មានតែ៤០សហគមន៍ប៉ុណ្ណោះ ដែលបានចុះបញ្ជី និងទទួលបានវិញ្ញាបនបត្របណ្ណសម្គាល់កម្មសិទ្ធិដីធ្លី មកទល់ពេលនេះ [២, ៥]។

***រូបភាពទី៤៖ ល្បឿនភាពនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច តាមឆ្នាំចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០២៣***




**ប្រភពទិន្នន័យ៖** ប្រព័ន្ធទិន្នន័យនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច, LANDESA, រាជធានីភ្នំពេញ, ឆ្នាំ២០២៤

- **រូបភាពទី៤ បង្ហាញថា៖**
  - សម្រាប់រយៈពេល១៣ឆ្នាំ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០២៣ មានសហគមន៍ជនជាតិដើមភាគតិច ត្រឹមមួយភាគបួនប៉ុណ្ណោះ ដែលបានចុះបញ្ជីកម្មសិទ្ធិដីធ្លី ដែលតាមការប៉ាន់ប្រមាណជាមធ្យមមានសហគមន៍ជនជាតិដើមភាគតិចតែ៣ប៉ុណ្ណោះ ដែលត្រូវបានគេចុះបញ្ជីក្នុងមួយឆ្នាំៗ [៥] ។

- ប្រសិនបើរាជរដ្ឋាភិបាល មានបំណងបិទបញ្ចប់ការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍នៅកម្ពុជាក្នុងរយៈពេល១០ឆ្នាំខាងមុខ រាជរដ្ឋាភិបាលចាំបាច់ត្រូវពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការចុះបញ្ជីយ៉ាងហោចណាស់៣ដង។

***ផែនទី ទី២៖ របាយការណ៍ចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច នៅតាមបណ្តាខេត្តទាំង៤ ក្នុងឆ្នាំ២០២៣***




**ប្រភពទិន្នន័យ៖** របាយការណ៍ស្តីពី ស្ថានភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម របស់ជនជាតិដើមភាគតិចនៅកម្ពុជា, ក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ, រាជធានីភ្នំពេញ, ឆ្នាំ២០២១ និងប្រព័ន្ធទិន្នន័យនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច, LANDESA, រាជធានីភ្នំពេញ, ឆ្នាំ២០២៤

**ផែនទី ទី២ បង្ហាញថា៖**

- វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិដីធ្លីសហគមន៍ ត្រូវបានចែកជូនដល់ប្រជាពលរដ្ឋជនជាតិដើមភាគតិចនៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង។
- ប៉ុន្តែសហគមន៍ជនជាតិដើមភាគតិចតិចជាង៥០%ប៉ុណ្ណោះ នៅក្នុងខេត្តទាំងនោះ បានទទួលវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិដីធ្លី។
- ជាឧទាហរណ៍ សហគមន៍ជនជាតិដើមភាគតិច ចំនួន ៣៦%នៅរតនគិរី ៣០.៧៧%នៅក្រចេះ ២៥% នៅខេត្តមណ្ឌលគិរី និង ១៤.២៨%នៅស្ទឹងត្រែង បានទទួលវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិដីធ្លី [២, ៥]។

## អត្រានៃភាពក្រីក្ររបស់សហគមន៍ជនជាតិដើមភាគតិច នៅតាមបណ្តាខេត្ត

***ផែនទី ទី៣៖ អត្តសញ្ញាណគ្រួសារក្រីក្រ តាមបណ្តាខេត្ត ក្នុងឆ្នាំ២០២៤***




**ប្រភពទិន្នន័យ៖** ក្រសួងផែនការ, កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ នៅកម្ពុជា, ភ្នំពេញ, នាយកដ្ឋានកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ឆ្នាំ២០២៤

**ផែនទី ទី៣ បង្ហាញថា៖**

- ក្នុងចំណោមខេត្តទាំង១០ ដែលមាន សហគមន៍ជនជាតិដើមភាគតិចរស់នៅ មានខេត្តចំនួន៦ ដែលមាន អត្រានៃភាពក្រីក្រខ្ពស់ (លើសពី២០%) និងខេត្តចំនួន ៤ ដែលមាន អត្រានៃភាពក្រីក្រមធ្យមនៅឆ្នាំ២០២៤។
- ខេត្តដែលមាន អត្រានៃភាពក្រីក្រខ្ពស់ មានខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ធំ បាត់ដំបង និងកោះកុង។
- ខេត្តដែលមានអត្រានៃភាពក្រីក្រមធ្យម មានខេត្តពោធិ៍សាត់ កំពង់ស្ពឺ ព្រះវិហារ និងស្ទឹងត្រែង[៦]។

*ផែនទី ទី៤៖ អត្តសញ្ញាណគ្រួសារក្រីក្រ តាមបណ្តាស្រុក ក្នុងឆ្នាំ២០២៤*




**ប្រភពទិន្នន័យ៖** ក្រសួងផែនការ, កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ នៅកម្ពុជា, ភ្នំពេញ, នាយកដ្ឋានកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ឆ្នាំ២០២៤

**ផែនទី ទី៤ បង្ហាញថា៖**

- នៅកម្រិតថ្នាក់ស្រុក ស្រុកថ្មបាំងនៃខេត្តកោះកុង ស្រុកត្បែងមានជ័យនៃខេត្តព្រះវិហារ និងស្រុកវើនសៃនៃខេត្តរតនគិរី គឺជាស្រុកដែលមានអត្រានៃភាពក្រីក្រច្រើនជាងគេបំផុត ពោលគឺ មានជាង ៣០% នៃគ្រួសាររស់នៅក្នុងភាពក្រីក្រនៅឆ្នាំ២០២៤ [៦]។

## គ្រួសារសហគមន៍ជនជាតិដើមភាគតិច ដែលមានស្ត្រីជាមេគ្រួសារ នៅតាមបណ្តាខេត្ត

*ផែនទី ទី៥៖ គ្រួសារដែលស្ត្រីជាមេគ្រួសារ តាមបណ្តាខេត្ត ក្នុងឆ្នាំ២០២២*




**ប្រភពទិន្នន័យ៖** ក្រសួងមហាផ្ទៃ, ប្រព័ន្ធទិន្នន័យឃុំ/សង្កាត់, រាជធានីភ្នំពេញ, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ឆ្នាំ២០២២

**ផែនទី ទី៥ បង្ហាញថា៖**

- ខេត្តកោះកុង ពោធិ៍សាត់ កំពង់ធំ និងបាត់ដំបង មានអត្រាស្ត្រីជាមេគ្រួសារខ្ពស់បំផុត ក្នុងឆ្នាំ២០២២ (លើលពី ១៥,៥%) [៧]។
- ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះដែលជាខេត្តមានសហគមន៍ជនជាតិដើមភាគតិចរស់នៅច្រើន មានអត្រាស្ត្រីជាមេគ្រួសារតិចបំផុតនៅឆ្នាំ២០២២ (ក្រោម ១០%) [៧]។

### *ផែនទី ទី៦៖ គ្រួសារដែលស្ត្រីជាមេគ្រួសារ តាមបណ្តាស្រុក ក្នុងឆ្នាំ២០២២*




**ប្រភពទិន្នន័យ៖** ក្រសួងមហាផ្ទៃ, ប្រព័ន្ធទិន្នន័យឃុំ/សង្កាត់, រាជធានីភ្នំពេញ, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ឆ្នាំ ២០២២

**ផែនទី ទី៦ បង្ហាញថា៖**

- នៅកម្រិតថ្នាក់ស្រុក ស្រុកថ្មបាំង នៃខេត្តកោះកុង និងស្រុកសំឡូត នៃខេត្តបាត់ដំបង មានអត្រាស្ត្រីជាមេគ្រួសារខ្ពស់បំផុតនៅឆ្នាំ២០២២ (លើសពី ១៥%) [៧]។
- ស្រុកតាវែង និងកូនមុំ នៃខេត្តរតនគិរី ស្រុកសែនមនោរម្យ និងអូររាំង នៃខេត្តមណ្ឌលគិរី និងស្រុកសៀមបូកនៃខេត្តស្ទឹងត្រែង គឺជាស្រុកដែលមានអត្រាស្ត្រីជាមេគ្រួសារក្នុងកម្រិតមធ្យម នៅឆ្នាំ២០២២ (១០-១៥%) [៧]។

## អំពើហិង្សាក្នុងគ្រួសាររបស់សហគមន៍ជនជាតិដើមភាគតិច នៅតាមបណ្តាខេត្ត

### *ផែនទី ទី៧៖ អំពើហិង្សាក្នុងគ្រួសារ តាមបណ្តាខេត្ត ក្នុងឆ្នាំ២០២២*




**ផែនទី ទី៧ បង្ហាញថា៖**

- ខេត្តព្រះវិហារ និងខេត្តរតនគិរី គឺជាខេត្ត ដែលមានកម្រិតនៃអំពើហិង្សាក្នុងគ្រួសារខ្ពស់បំផុត នៅក្នុងឆ្នាំ២០២២ (ច្រើនជាង៧៥ ក្នុងចំណោម ១០ ០០០គ្រួសារ) [៧]។

**ប្រភពទិន្នន័យ៖** ក្រសួងមហាផ្ទៃ, ប្រព័ន្ធទិន្នន័យឃុំ/សង្កាត់, រាជធានីភ្នំពេញ, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ឆ្នាំ២០២២

## *ផែនទី ទី៨៖ អំពើហិង្សាក្នុងគ្រួសារ តាមបណ្តាស្រុក ក្នុងឆ្នាំ២០២២*




**ប្រភពទិន្នន័យ៖** ក្រសួងមហាផ្ទៃ, ប្រព័ន្ធទិន្នន័យឃុំ/សង្កាត់, រាជធានីភ្នំពេញ, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ឆ្នាំ២០២២

**ផែនទី ទី៨ បង្ហាញថា៖**

- ស្រុកភាគច្រើននៅក្នុងខេត្ត ក្រចេះ រតនគិរី មណ្ឌលគិរី និង ស្ទឹងត្រែង មានអត្រាប្រេវ៉ាឡង់ ខ្ពស់នៃអំពើហិង្សាក្នុងគ្រួសារ ក្នុង ឆ្នាំ២០២២ (ច្រើនជាង៧៥ ក្នុង ចំណោម ១០ ០០០គ្រួសារ) [៧]។

## សេចក្តីសង្ខេប

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់ថា សុវត្ថិភាពដីធ្លី គឺជាមធ្យោបាយមួយ សម្រាប់ជួយកាត់បន្ថយភាពក្រីក្រ និងធានាបាននូវជីវភាពរស់នៅប្រកបដោយចីរភាពរបស់ជនជាតិដើមភាគតិច ។
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានទទួលស្គាល់ផងដែរថា ការចុះបញ្ជីដីធ្លីសម្រាប់ជនជាតិដើមភាគតិច គឺជាការធានានូវសុវត្ថិភាពដីធ្លីជូនពួកគាត់។
- ទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា នៅមានភាពយឺតយ៉ាវនៅឡើយ។ ជាក់ស្តែងមានសហគមន៍ជនជាតិដើមភាគតិច ត្រឹមមួយភាគបួនប៉ុណ្ណោះ ដែលត្រូវបានចុះបញ្ជីកម្មសិទ្ធិដីធ្លី គិតត្រឹមឆ្នាំ២០២៣។
- ក្នុងចំណោមបណ្តាខេត្តនៅភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា ដែលមានសហគមន៍ជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ ខេត្តរតនគិរី គឺជាខេត្តដ៏មានសក្តានុពលមួយ ដែលសភាកម្ពុជាអាចពិចារណាក្នុងការចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ ពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច ដែលនៅសេសសល់។
- ការកំណត់យកខេត្តរតនគិរីនេះ គឺដោយសារខេត្តនេះមាន ១)អត្រាសហគមន៍ដែលមិនទាន់ចុះបញ្ជីកម្មសិទ្ធិដីធ្លីច្រើនជាងគេ ២)អត្រានៃភាពក្រីក្រច្រើនជាងគេ ៣) អាត្រាអំពើហិង្សាក្នុងគ្រួសារ និងស្ត្រីជាមេគ្រួសារច្រើននិងមធ្យម។

- ឯកសារជំនួយស្មារតីនេះ ក៏បង្ហាញយ៉ាងជាក់ច្បាស់នូវស្រុកមួយចំនួន ដូចជាស្រុកតាវែង អណ្តូងមាស និងស្រុកអូរជុំនៃខេត្តរតនគិរី ដែលសភាកម្ពុជាអាចចុះពិនិត្យស៊ើបអង្កេតរកអង្គហេតុជាក់លាក់នានា ចំពោះភាពយឺតយ៉ាវ និងបញ្ហាប្រឈមក្នុងការអនុវត្តការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិច នៅព្រះរាជាណាចក្រកម្ពុជា។

## ឯកសារយោង


[១] Cambodian Centre for Human Rights. (2016). Cambodia’s Women in Land Conflict. Cambodian Centre for Human Rights. Cambodia’s Women in Land Conflict (cchrcambodia.org).

[២] Ministry of Planning and Ministry of Rural Development. (2021). Report on the Demographic and

[៣] GDANCP. (2017). Zoning Guidelines for the Protected Areas in Cambodia. Phnom Penh, Cambodia: General Directorate of Administration for Nature Conservation and Protection (GDANCP), the Ministration of Environment

[៤] RGC (2002). Preah Reach Kram NS/RKM/0802/016 on Law on Forestry. Phnom Penh, Cambodia.

[៥] LANDESA. (2024). Indigenous Community Land Titling Database. Phnom Penh, Cambodia.

Socio-Economic Situation of Indigenous Peoples in Cambodia. Phnom Penh, Cambodia.

[៦] Ministry of Planning. (2024). The Identification of Poor Households Programme in Cambodia. Department of Identification of Poor Households. IDPoor (https://app.idpoor.gov.kh)

[៧] Ministry of Interior. (2022). Commune Database of National Committee for Subnational Democratic Development. Phnom Penh, Cambodia.